# សេរីភាពមូលដ្ឋាន
## ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ បានប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ។ ចាប់តាំងពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន *បានកត់ត្រានូវហេតុការណ៍ចំនួន ៥៦ករណី **ពាក់ព័ន្ធនឹងការបោះឆ្នោត ដែលជាប់ទាក់ទងនឹងការរឹតត្បិត ឬ ការរំលោភបំពានទៅលើសេរីភាពមូលដ្ឋាន។ ***ទិន្នន័យត្រូវបានប្រមូលមកតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានប្រចាំថ្ងៃ និងការរាយការណ៍ពីហេតុការណ៍។




ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ទាមទាមឱ្យគោរពសិទ្ធិផ្សេងៗក្នុងចំណោមនោះរួមទាំងបរិយាកាសប្រសើរនៃសេរីភាពមូលដ្ឋាន និងមានការចូលរួមពីប្រជាពលរដ្ឋ។ សេរីភាពខាងការបញ្ចេញមតិ ពិតជាមានសារៈសំខាន់ណាស់ក្នុងការធានាថា សំឡេងរបស់បេក្ខជន អ្នកសារព័ត៌មាន និងពលរដ្ឋត្រូវផ្សព្វផ្សាយដើម្បីជាប្រយោជន៍សាធារណៈ។ ការគោរពសេរីភាពខាងសមាគមបានអនុញ្ញាតឱ្យគណបក្សនយោបាយទាំងឡាយអាចធ្វើការឃោសនាបោះឆ្នោត និងបង្ហាញវត្តមានរបស់បេក្ខជនឈរឈ្មោះ។ សេរីភាពខាងការជួបប្រជុំ អាចឱ្យមានការជួបប្រជុំរវាងអ្នកគាំទ្រគណបក្ស និងផ្សព្វផ្សាយសាររបស់គណបក្សនយោបាយបានកាន់តែច្រើន។



## សេរីភាពខាងសមាគម

ហេតុការណ៍ចំនួន ៥៤ បានប៉ះពាល់ដល់សេរីភាពខាងសមាគម ដែលក្នុងនោះមាន ៥៣ ករណី កំណត់មុខសញ្ញាមកលើគណបក្សនយោបាយ។ គណបក្សភ្លើងទៀន បានប្រឈមខ្លាំងជាងគេ ដែលក្នុងនោះមានហេតុការណ៍ចំនួន ៤៣ ករណី ត្រូវបានការកត់ត្រា។ គណបក្សនយោបាយផ្សេងទៀត ដែលជួបប្រទះនឹងការរឹតត្បិតមានដូចជា គណបក្សបេះដូងជាតិ គណបក្សកែទម្រង់កម្ពុជា គណបក្សកម្ពុជានិយម គណបក្សខ្មែរស្រលាញ់ជាតិ គណបក្សឆន្ទៈខ្មែរ និងគណបក្សប្រជាធិបតេយ្យមូលដ្ឋាន។

នៅក្នុង ១៤ ហេតុការណ៍ គណបក្សនយោបាយ និងសកម្មជន បានប្រឈមនឹងវិធានការផ្លូវច្បាប់។ ហេតុការណ៍ទាំងអស់នេះ បានធ្វើឱ្យបុគ្គលដែលជាប់ពាក់ព័ន្ធ ឬ គណបក្សនោះ បានអះអាងថា វិធានការផ្លូវច្បាប់ដែលពួកគេបានប្រឈមនេះគឺបណ្ដាលមកពីរឿងនយោបាយ។ នៅក្នុងហេតុការណ៍ពីរផ្សេងគ្នា បេក្ខជនគណបក្សភ្លើងទៀន ត្រូវបានកោះហៅមកសាកសួរទាក់ទងនឹងបទញុះញង់ កាលពីឆ្នាំ ២០១៩ និង ២០២១ មកម្ល៉េះ។ ករណីទាំងពីរនេះ បុគ្គលដែលជាប់ពាក់ព័ន្ធបានយល់ឃើញថា ពេលវេលានៃការកោះហៅគឺគួរឱ្យសង្ស័យ និងក្នុងគោលបំណង បំភិតបំភ័យពួកគេឱ្យផ្អាកសកម្មភាពនយោបាយ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានលុបឈ្មោះបេក្ខជនគណបក្សជំទាស់មួយចំនួនមិនឱ្យឈរឈ្មោះបោះឆ្នោត ដោយលើកឡើងពីការខុសទម្រង់នៃការចុះឈ្មោះរបស់ខ្លួន។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានកត់ត្រាបេក្ខជនចំនួន ១៨៣ នាក់ ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះបោះឆ្នោត។ មានយ៉ាងតិច ៣ ករណី គ.ជ.ប បានថ្លែងពីភាពមិនប្រក្រតីចំពោះការចុះបញ្ជីបេក្ខជនមួយចំនួន និងលុបបញ្ជីឈ្មោះទាំងស្រុងពីបេក្ខភាពឈរឈ្មោះបោះឆ្នោតឃុំសង្កាត់ ជាជាងបង្ហាញពីគុណសម្បត្តិមិនគ្រប់គ្រាន់របស់បេក្ខជនជាក់លាក់ដែលពាក់ព័ន្ធនៅក្នុងបញ្ជីនោះ។ ការណ៍នេះនាំឱ្យគណបក្សប្រជាជនកម្ពុជា ដំណើរការដោយមិនមានការប្រកួតប្រជែងនៅក្នុងឃុំសង្កាត់នោះ។ ការប៉ាន់ប្រមាណនៅកន្លែងផ្សេងទៀតបេក្ខជនជំទាស់ដែលត្រូវបានដកឈ្មោះចេញពីបញ្ជីគឺមានចំនួនច្រើនជាង ៣០០នាក់។



នៅក្នុងហេតុការណ៍ចំនួន ៧ ករណី មានអំពើហិង្សាបានកើតឡើងសំដៅមកលើសមាជិកគណបក្សនយោបាយមិនកាន់អំណាច ឬទ្រព្យសម្បត្តិរបស់ពួកគេ។ ក្នុងចំណោមហេតុការណ៍ទាំង ៧ នោះ មានហេតុការណ៍ចំនួន ១ ដែលភាគីទីបីម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថាជាជនល្មើស។ ជនរងគ្រោះចំនួន ២នាក់ បាននិយាយថា ពួកគេនឹងមិនដាក់ពាក្យបណ្ដឹងនោះទេ ដោយសារតែមិនមានភាពជឿជាក់ទៅលើអាជ្ញាធរក្នុងការរកយុត្តិធម៌ឱ្យខ្លួន។



Cambodian Center for Human Rights · ADHOC · Solidarity Center · ICNL International Center for Not-for-Profit Law

ខែកក្កដា ឆ្នាំ២០២២

CC BY NC SA

# សេរីភាពខាងការបញ្ចេញមតិ

មានហេតុការណ៍ចំនួន ២០ ករណី បានប៉ះពាល់ទៅដល់សេរីភាពខាងការបញ្ចេញមតិ។ ក្នុងនោះមានហេតុការណ៍ចំនួន១៦ ករណី ទាក់ទងនឹងការរារាំងមកលើការលើកស្លាកគណបក្សនយោបាយរបស់គណបក្សផ្សេងទៀត។ ហេតុការណ៍ទាំងអស់នេះ រួមមានអាជ្ញាធរបានបញ្ជាឱ្យគណបក្សនយោបាយមួយចំនួនទម្លាក់ស្លាក ឬ រារាំងក្នុងការលើកស្លាក ដោយពេលខ្លះលើកឡើងពីហេតុផលប៉ះពាល់ដល់ការធ្វើចរាចរណ៍ទៀតផង។ គណបក្សដែលបានចុះឈ្មោះ មិនចាំបាច់ត្រូវការការយល់ព្រមពីអាជ្ញាធរមូលដ្ឋានក្នុងការលើកស្លាកសញ្ញារបស់ខ្លួនឡើយ។ មានស្លាកសញ្ញារបស់គណបក្សនយោបាយចំនួន ២ ត្រូវបានភាគីទីបីបំផ្លាញ។





មានហេតុការណ៍ចំនួន ១ ដែលព្រះសង្ឃមួយអង្គត្រូវបណ្តេញចេញពីវត្ត ដោយសារតែមិនព្រមឈប់ផ្សព្វផ្សាយសារគាំទ្រគណបក្សភ្លើងទៀនតាមអ៊ីនធឺណិត។

អ្នកសារព័ត៌មាន ត្រូវបានសួរនាំឱ្យបង្ហាញអត្តសញ្ញាណរបស់ខ្លួន និងបង្ហាញប័ណ្ណសារព័ត៌មាន ព្រមទាំងបានឃ្លាំមើល និងតាមដានដោយអាជ្ញាធរនៅពេលដែលពួកគេកំពុងតែសម្ភាសន៍អ្នកស្រុកនៅខេត្តកណ្តាលអំពីការបោះឆ្នោតឃុំសង្កាត់។ អ្នកស្រុកមួយចំនួនមិនហ៊ានបញ្ចេញមតិ ដោយសារតែអាកប្បកិរិយារបស់អាជ្ញាធរ ក្នុងនោះមានបុរសម្នាក់បាននិយាយថា គាត់មិន "ហ៊ាន" និយាយនោះទេ ព្រោះ "នឹងមានគេមក និងតាមឃ្លាំមើលពួកគាត់"។






# សេរីភាពខាងការជួបប្រជុំ

សំណើដង្ហែក្បួនរបស់គណបក្សភ្លើងទៀនក្នុងការឃោសនាបក្សនៅទីប្រជុំជន និងតំបន់កណ្តាលក្រុងដែលជាផ្នែកមួយនៃការប្រមូលផ្តុំសមាជិករបស់ខ្លួន ត្រូវបានអាជ្ញាធរនៅខេត្តកណ្តាលបដិសេធចំនួន ០៤ លើក ដោយលើកហេតុផល "ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ"។



ដើម្បីឱ្យមានលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោតត្រូវតែប្រព្រឹត្តឡើងដោយសេរី និងយុត្តិធម៌។ ការបោះឆ្នោត គឺអាចប្រព្រឹត្តទៅដោយសេរី ប្រសិនបើអនុញ្ញាតឱ្យពលរដ្ឋសម្តែងនូវឆន្ទៈនយោបាយរបស់ខ្លួនឱ្យបានពេញលេញ ដែលតម្រូវឱ្យមានបរិយាកាសមួយដែលមានសុវត្ថិភាព ដើម្បីឱ្យបុគ្គលនីមួយៗមានភាពជឿជាក់ថាពួកគេនឹងមិនប្រឈមនឹងការសងសឹកដោយសារតែការចូលរួមរបស់ខ្លួន។ ការបោះឆ្នោត គឺអាចធ្វើឡើងដោយយុត្តិធម៌ផងដែរ ប្រសិនបើ គណបក្សនយោបាយទាំងអស់ និងបេក្ខជនឈរឈ្មោះ អនុវត្តនូវសិទ្ធិនយោបាយ និងសេរីភាពរបស់ខ្លួនបានដូចគ្នា។

*គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ជាគម្រោងឃ្លាំមើលលំហសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា រួមទាំងលទ្ធភាពក្នុងការអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។

**ហេតុការណ៍ត្រូវបានកត់ត្រារាល់ការរឹតត្បិតឬរំលោភបំពានលើសេរីភាពមូលដ្ឋានដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ឬរាយការណ៍ដោយផ្ទាល់មកក្រុមការងារគម្រោងដោយបុគ្គលម្នាក់ៗ ឬសមាគម។ ភាពខុសគ្នារវាងការរឹតត្បិត និងការរំលោភបំពានសិទ្ធិអាចធ្វើបានដោយមានច្បាប់អនុញ្ញាតជាក់លាក់ ខណៈពេលដែលការរំលោភបំពានផ្ទុយពីបទដ្ឋានច្បាប់អន្តរជាតិ។

*** ចំនួនហេតុការណ៍សរុបមានទាបជាងចំនួនហេតុការណ៍ដែលកើតឡើងមកលើសេរីភាពនីមួយៗដោយសារតែ ក្នុងចំណោមហេតុការណ៍ចំនួន១ អាចពាក់ព័ន្ធមកលើសេរីភាពលើសពី១។

ខែកក្កដា ឆ្នាំ២០២២

CC BY NC SA